ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៦ សសរ

សេចក្តីសម្រេច

ស្តីពី

ការអនុវត្តន៍ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ៥ ជំពូក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពី ការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មមាត្រា ៤ មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៩៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

ស ម្រេ ច

ប្រការ ១ :

ត្រូវបានដាក់អោយអនុវត្តនូវស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ៥ជំពូក ដូចខាងក្រោម :

- ជំពូក ១. ការអនុវត្តស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា
- ជំពូក ២. ប័ណ្ណទទួលស្គាល់អង្គការប្រតិបត្តិករសកម្មភាពកំចាត់មីន និង ការផ្តល់អាជ្ញាប័ណ្ណសម្រាប់កិច្ចប្រតិបត្តិការ
- ជំពូក ៣. ការត្រួតពិនិត្យប្រតិបត្តិករដោះមីន
- ជំពូក ៤. ការរក្សាទុក ការដឹកជញ្ជូន និង ការប្រើប្រាស់វត្ថុផ្ទុះ
- ជំពូក ៥. សេចក្តីរាយការណ៍ និង ការអង្កេតឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងពេលដោះមីន ។

ប្រការ ២ :

គ្រប់ប្រតិបត្តិករដែលមានបំណងធ្វើសកម្មភាពបោសសំអាតមីន ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំប័ណ្ណទទួលស្គាល់ និង ចុះកិច្ចសន្យាជាមួយអគ្គលេខាធិការអាជ្ញាធរមីន ។

ប្រការ ៣ :

ប្រតិបត្តិករដោះមីនជាតិ និង អន្តរជាតិ ដែលកំពុងបើកកិច្ចប្រតិបត្តិការបោសសំអាតមីននៅកម្ពុជា ត្រូវមកបំពេញបែបបទចុះកិច្ចសន្យា ដើម្បីធ្វើនិយតកម្មជាមួយអគ្គលេខាធិការអាជ្ញាធរមីន ក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ ។

ប្រការ ៤ :

អគ្គលេខាធិការដ្ឋានអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ត្រូវរៀបចំចងក្រងគោលការណ៍ណែនាំលំអិត ដើម្បីអនុវត្តនូវស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា អោយមានប្រសិទ្ធភាព ។

ប្រការ ៥ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

www.pheakdeylaw.com

ប្រការ ៦ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ និង អគ្គលេខាធិការអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com